long beach unified school district

កម្មវិធីបង្គាត់ BP 6020

## <u>ការរួមចំណែកនៃមាតាបិតា</u>

គណៈកម្មាធិការចាត់ចែងកម្មវិធីសិក្សា ទទួលស្គាល់ថា មាតាបិតា/អ្នកគ្រប់គ្រងសិស្ស គឺជាគ្រូបង្រៀនទីមួយរបស់សិស្សដែលមានឥទ្ធិពលច្រើនបំផុត ហើយការបន្តផ្នែករួមចំណែកនៃមាតាបិតាមកលើកម្មវិធីសិក្សា គឺនាំមកប្រយោជន៍សម្បើមណាស់សំរាប់សិស្ស និង កន្លែងរៀនសូត្រត្រឹមត្រូវនៅក្នុងសាលារៀន ។ ដោយមូលហេតុនេះ គឺគណៈកម្មាធិការនឹងរក្សាទុកអំពីច្បាប់សរសេររបៀបរាប់ផ្នែករួមចំណែកនៃមាតាបិតា ដែលត្រូវបានបង្កើតរួម និង យល់ស្របតាមដោយមាតាបិតា/អ្នកគ្រប់គ្រងសិស្ស ហើយអាចប្រើត្រឹមត្រូវបាននៅតាមសាលារៀនផ្សេងៗ ដែលគ្មានទទួលជំនួយមកពី Title I ។

ដើម្បីទាក់ទាញមាតាបិតា/អ្នកគ្រប់គ្រងសិស្សឲ្យចូលរួមចំណែកយ៉ាងស្និទ្ធស្នាលជាមួយកម្មវិធីសិក្សានៃសិស្ស គឺអគ្គនាយកក្រសួងសិក្សាធិការ ឬ បុគ្គលិកទទួលមុខងារជំនួសនឹងធ្វើការពិនិត្យតាមដានអំពីភាពសក្តិសិទ្ធនៃការរួមចំណែកមកពីមាតាបិតា ដើម្បីបញ្ជាក់ឲ្យដឹងថា បុគ្គលិកនៅតាមសាលារៀននិមួយៗនឹង ...

1. ជួយមាតាបិតា/អ្នកគ្រប់គ្រងសិស្សបណ្តុះចំណេះផ្នែកអប់រំ និង ផ្តល់ឱកាសល្អនៅក្នុងផ្ទះសំរាប់គាំទ្រលើការរៀនសូត្រនៃសិស្ស និង ភាពលូតលាស់របស់គេក្នុងនាមជាសមាជិកក្នុងសង្គម ។

2. ជំរាបប្រាប់មាតាបិតា/អ្នកគ្រប់គ្រងសិស្សឲ្យជ្រាបថា ពួកគាត់អាចជះឥទ្ធិពលមកលើសេចក្តីជោគជ័យផ្នែករៀនសូត្រនៃសិស្សរបស់ពួកគាត់បាន ដោយបង្ហាញពួកគាត់អំពីមធ្យោបាយច្រើនយ៉ាង ដែលអាចប្រើបានសំរាប់ជួយបង្កើនសេចក្តីជោគជ័យផ្នែករៀនសូត្រ និង ការរៀនសូត្រទូទៅនៃសិស្សរបស់ពួកគាត់នៅឯផ្ទះ ។

3. បង្កើនទំនាក់ទំនងរវាងសាលារៀន និង ផ្ទះ ដែលមានភាពសក្តិសិទ្ធ ដើម្បីផ្តល់ឱកាសសំរាប់មាតាបិតា/អ្នកគ្រប់គ្រងសិស្សអាចទទួលដឹងអំពីពេលវេលា និង របៀបជួយសិស្សរបស់ពួកគាត់ផ្នែករៀនសូត្រនៅតាមបន្ទប់ថ្នាក់ និង ដើម្បីបញ្ជាក់ថា ក្រដាសស្នាម, សំបុត្រ និង របាយការណ៍ផ្សេងៗត្រូវបានសរសេរបកប្រែជូនមាតាបិតា/អ្នកគ្រប់គ្រងសិស្សជាភាសាកំណើតរបស់ពួកគាត់មែន ។

4. បុគ្គលិកសាលារៀននឹងបានទទួលកម្មវិធីហ្វឹកហ្វឺនផ្នែកបង្កើនភាពសក្តិសិទ្ធ និង ទំនាក់ទំនងជាមួយគ្រួសារនៅតាមផ្ទះ ដោយចំណាំទុកអំពីប្រពៃណីច្រើនចំណែកថែមទាំងរាប់បញ្ចូលផងអំពីកម្មវិធីហ្វឹកហ្វឺនបង្កើតទំនាក់ទំនងជាមួយមាតាបិតានៃសិស្ស ដែលមិនចេះភាសា អង់គ្លេស និង របៀបផ្តល់ឱកាសជូនមាតាបិតា/អ្នកគ្រប់គ្រងសិស្សអំពីរបៀបជួយបង្ហាត់មេរៀនដល់សិស្សរបស់ពួកគាត់ទាំងនៅក្នុងសាលារៀន ទាំងនៅក្នុងផ្ទះ ។

5. លើកទឹកចិត្តមាតាបិតា/អ្នកគ្រប់គ្រងសិស្សឲ្យចំណាយពេលស្ម័គ្រចិត្តជួយកិច្ចការនៅតាមសាលារៀនសាធារណៈ, ចូលរួមគាំទ្រកម្មវិធីសម្តែងនៃសិស្សនៅក្នុងសាលារៀន, កម្មវិធីប្រជុំទូទៅនៅក្នុងសាលារៀន, កម្មវិធីប្រជុំ ក្រុមប្រឹក្សាប្រចាំសាលារៀន, ក្រុមប្រឹក្សាផ្តល់ឱវាទ និង កម្មវិធីប្រជុំផ្សេងៗ ដែលពួកគាត់អាចមានមុខងារជាអ្នកដោះស្រាយ និង ផ្តល់ឱវាទបាន ។

6. រាប់បញ្ចូលមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សរៀនភាសា អង់គ្លេស (English Language Learners) ក្នុងការបង្កើត, ប្រើធ្វើតាម និង ស្ទង់មើលឡើងវិញអំពីកម្មវិធីសំខាន់ៗ ដែលត្រូវចំណាយថវិការសំរាប់ជួយសិស្សរៀនភាសា អង់គ្លេស ។ ជំរាបមាតាបិតាអំពីរបៀបពួកគាត់អាចចូលរួមចំណែកបាននៅក្នុងកម្មវិធីសិក្សានៃសិស្សរបស់ពួកគាត់ និង ចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយសិស្សនៃពួកគាត់ឲ្យឆាប់ចេះប្រើភាសា អង់គ្លេស ស្ទាត់ និង រៀនសូត្រដល់កម្រិតខ្ពង់ខ្ពស់តាមមុខវិជ្ជាសំខាន់ៗដែលជាខ្នាតគំរូសិក្សាចែងចេញមកពីរដ្ឋសំរាប់ទុកឲ្យសិស្សទាំងអស់ប្រឹងប្រែងរៀនសូត្រតាម ។

នៅពេលណាមានចំនួនសិស្សនៅតាមសាលារៀនពី 15% ឬ លើសឡើងទៅ ដែលនិយាយភាសាកំណើតផ្សេងនៅឯផ្ទះ ក្រៅពីភាសា អង់គ្លេស គឺមានន័យថា ក្រដាសស្នាម, សំបុត្រ និង របាយការណ៍ទាំងអស់ ដែលផ្ញើជូនមាតាបិតា (រាប់បញ្ចូលទាំងក្រសួងអប់រំ ឱស្រ្ទីគ ផង) គឺនឹងសរសេរបង្ហាញជាភាសា អង់គ្លេស ដោយរាប់បញ្ចូលទាំងភាសាកំណើតរបស់ពួកគាត់នៅឯផ្ទះផង ។

មាតាបិតាក៏អាចស្នើសុំឲ្យមានការនិយាយពន្យល់បកប្រែជាភាសាកំណើតបានដែរអំពីក្រដាសសំណុំរឿងអ្វីមួយ (Education Code 48985) ។

គម្រោងការណ៍សាលារៀនត្រូវរៀបរាប់បង្ហាញចំណុចច្បាស់លាស់ ដែលត្រូវធ្វើតាម ដើម្បីបង្កើនការរួមចំណែកមកពីមាតាបិតាជាមួយកម្មវិធីសិក្សានៃសិស្សរបស់ពួកគាត់ ដោយរាប់បញ្ចូលទាំងរបៀបត្រូវធ្វើសំរាប់ទាក់ទាញមាតាបិតា/អ្នកគ្រប់គ្រងសិស្ស ដែលមានបញ្ហាផ្នែកភាសា, ប្រពៃណី និង អ្វីផ្សេងៗ ដែលអាចជាឧបសគ្គរាំងស្ទះ ឲ្យមានចំណែកចូលរួមផង ។

ដកស្រង់មកពីច្បាប់

EDUCATION CODE
11500-11506 កម្មវិធីសំរាប់លើកទឹកចិត្តផ្នែករួមចំណែកនៃមាតាបិតា

LABOR CODE
230.8 ពេលវេលាពីការងារសំរាប់ប្រើពិនិត្យនៅតាមសាលារៀននៃសិស្ស

| | |
|---|---|
| បានបង្កើតឡើងនៅៈ | ថ្ងៃទី28 ខែមករា ឆ្នាំ1991 |
| បានកែប្រែឡើងវិញនៅៈ | ថ្ងៃទី1 ខែមិនា ឆ្នាំ1994 |
| | ថ្ងៃទី6 ខែកុម្ភៈ ឆ្នាំ2001 |
| | ថ្ងៃទី7 ខែមិនា ឆ្នាំ2007 |
| | ថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2010 |

LONG BEACH UNIFIED SCHOOL DISTRICT